នស/រកត/០៦០២/១៥៤

# ព្រះរាជក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស, អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ស.រ.

## ត្រាស់បន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.—**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចមានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.—**

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ប្រមូលផ្ដុំមន្ត្រីដែលមានមុខងារក្នុងការប្រតិបត្តិផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្ដាល និងខេត្តក្រុង នៃក្រសួង ស្ថាប័ន ។

**មាត្រា ៣.—**

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៤.—**

ក្របខ័ណ្ឌភ្នាក់បច្ចេកទេសមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិនាយភ្នាក់ងារបច្ចេកទេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិភ្នាក់ងារបច្ចេកទេសដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិភ្នាក់ងារបច្ចេកទេស មាន ១៤ ថ្នាក់ ។

## ជំពូកទី ២

## ការជ្រើសរើស

**មាត្រា ៥.—**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស រៀបចំដោយក្រសួង ស្ថាប័នសាមី ។

ចំនួនមុខតំណែងជ្រើសរើស ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមតំរូវការរបស់មុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។/.

**មាត្រា ៦.-**

ការប្រលងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជន ដែលមានកាយសម្បទាសមស្របតាមការងារ និងមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ដោយពុំគិតទូវទូវលក្ខខណ្ឌសញ្ញាប័ត្រអ្វីឡើយ ។

## ជំពូកទី ៣
## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្ដាល របស់ក្រសួង ស្ថាប័ន ហើយត្រូវបានតែងតាំងជាភ្នាក់ងារបច្ចេកទេសកម្មសិក្សាដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ។

កម្មសិក្សានេះមានរយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរ ស័ក្តិទី ៣ ដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៨.-**

ភ្នាក់ងារបច្ចេកទេស ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី ២នេះ ភ្នាក់ងារនោះត្រូវលុបឈ្មោះចេញ។

## ជំពូកទី ៤
## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ៩.-**

ភ្នាក់ងារបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យតំលើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។ ៚

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១០._

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនិមួយៗ ត្រូវកំណត់ដូចតទៅ :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី ៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

មាត្រា ១១._

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាម មាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

មាត្រា ១២._

ភ្នាក់ងារបច្ចេកទេសត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

មាត្រា ១៣._

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែល បច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ នៅតាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់ កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន ។ល។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៥.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៦.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល.ៗ.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

៣ រស. ០២.០៦.០០១៦៤

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាយ ឈាន់**